ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ

សាលាឧទ្ធរណ៍ភ្នំពេញ

លេខ ៧១១/២៣-៧-១២

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៤-១២-១៣ ដែលមានសមាសភាពដូចតទៅ៖

**សាលដីកា**

លេខ ៧៨ក្រ៣.ឃ.ចុះ

ថ្ងៃទី ២៤-១២-២០១៣

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ៧១១ ចុះថ្ងៃទី ២៣-០៧-២០១២ រវាង ៖

-ជនជាប់ចោទឈ្មោះ

១-[redacted]**វណ្ណា** ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាលបង្ក្រាបគ្រឿងញៀន កើតនៅភូមិមាន់ដប់ ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម មានទីលំនៅផ្ទះលេខ [redacted] រាជធានី [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០៣នាក់ ទោសពីមុនគ្មាន (ឃុំខ្លួន)។ (ដើមបណ្តឹងឧទ្ធរណ៍)

២-[redacted]**ចាន់កេសរ** ភេទស្រី អាយុ៣៧ ជាតិខ្មែរ មុខរបរ នៅផ្ទះ កើតនៅភូមិស្តៅក្រោម ឃុំស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម មានទីលំនៅផ្ទះលេខ [redacted] ផ្លូវ [redacted] ឪពុកឈ្មោះ [redacted] ហៅ ជា សាម៉ូម៉"រ" ម្តាយឈ្មោះ [redacted] "រ" ប្តីទី១ឈ្មោះ [redacted] (លែងគ្នា) ប្តី ទី២ឈ្មោះ [redacted] "ស" ប្តីទី៣ឈ្មោះ [redacted] កូនចំនួន០២នាក់ទោសពីមុនគ្មាន(ដើមបណ្តឹងឧទ្ធរណ៍)។មានមេធាវីការពារឱ្យឈ្មោះ [redacted] ចន្ថា។



Scanned with CamScanner

៣-[redacted]ផាន ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើចំការ កើតនៅភូមិបឹងខ្វែក ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មានទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted]"រ" ប្រពន្ធឈ្មោះ អ៊ុំ សុជាន។" មានកូនចំនួន០៤នាក់ ទោសពីមុនគ្មាន (ឃុំខ្លួន)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted]ម៉ាំង។

៤-[redacted]អៀង ភេទប្រុស ជាតិខ្មែរ..................។

៥-[redacted]សារ៉ាត ភេទប្រុស ជាតិខ្មែរ.....................។

៦-[redacted]ចាន់ណា ភេទស្រី ជាតិខ្មែរ.......................។

**ត្រូវបានចោទពីបទ** ៖ លក់ដូរជួញដូរគ្រឿងញៀនច្រើនដង

ប្រព្រឹត្តនៅភូមិសាស្ត្រឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីដើមឆ្នាំ ២០០៦ ដល់ដើមឆ្នាំ ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី កថាខណ្ឌ២ ចំណុច"ក" នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ឯរឿងហេតុមានដូចតទៅ**

ចាប់ពីដើមឆ្នាំ ២០០៦ ដល់ដើមឆ្នាំ ២០០៧ ឈ្មោះ [redacted] អៀង បានទិញថ្នាំញៀនពីឈ្មោះ [redacted] ចាន់កេសរ ដើម្បីយកទៅលក់បន្តឱ្យឈ្មោះ [redacted] ផាន , [redacted] វណ្ណា , [redacted] ហៅ ម៉ែឃើល និងឈ្មោះ ដេវីត "ជនជាតិថៃ" ជាច្រើនលើកច្រើនសារ ហើយក៏មានឈ្មោះ [redacted] សារ៉ាត់ ហៅ ហេង និងឈ្មោះ [redacted] ចាន់ធា ហៅ ណាយ គឺជាមេរកស៊ីធំកាន់កាប់គ្រឿងញៀនផ្នែកទឹកកកផងដែរ។ នៅថ្ងៃទី ១០-១១-២០០៧ ឈ្មោះ [redacted] អៀង ត្រូវបានសមត្ថកិច្ចចាប់ខ្លួន-ឃុំខ្លួនក្នុងសំណុំរឿងលេខ ១៨២៥ ចុះថ្ងៃទី ២៦-១០-២០០៧ ចាប់ពីពេលនេះមកឈ្មោះ [redacted] វណ្ណា បានលក់គ្រឿងញៀនបន្តជំនួសឈ្មោះ [redacted] អៀង ឱយទៅម៉ូយទាំងអស់នោះក្នុងភូមិសាស្ត្រឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ រហូតចាប់ខ្លួនបាន។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៥"ច" ចុះថ្ងៃទី ១៧-០៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសលើ៖

ក/- ឈ្មោះ [redacted] ចាន់កេសរ ភេទស្រី កើតឆ្នាំ១៩៧៧ ដាក់ពន្ធនាគារកំណត់ ០៨(ប្រាំបី)ឆ្នាំ។

ខ/-ឈ្មោះ [redacted] ផាន ភេទប្រុស កើតឆ្នាំ ១៩៦៩ ដាក់ពន្ធនាគារកំណត់ ០៥(ប្រាំ) ឆ្នាំ។

គ/-ឈ្មោះ [redacted] អៀង ភេទប្រុស កើតឆ្នាំ ១៩៦៩ ដាក់ពន្ធនាគារកំនត់ ០២(ពីរ) ឆ្នាំ។

ឃ/-ឈ្មោះ [redacted] សារ៉ាត់ ហៅ ហេង ភេទប្រុស កើតឆ្នាំ ១៩៥៣ និងឈ្មោះ [redacted] ចាន់ណា ហៅ ណាយ ភេទស្រី កើតឆ្នាំ ១៩៧៨ ដាក់ពន្ធនាគារកំណត់ ០១(ដប់) ឆ្នាំ។

ពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ (ប្រព្រឹត្តច្រើនដង) ប្រព្រឹត្តនៅភូមិសាស្ត្រ ឃុំប៉ោយ-



Scanned with CamScanner

ប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីដើមឆ្នាំ ២០០៦ ដល់ដើមឆ្នាំ ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី កថាខណ្ឌ២ ចំណុច"ក" នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០០៥។

២-ផ្តន្ទាទោសឈ្មោះ [redacted] វណ្ណា ភេទប្រុស កើតឆ្នាំ ១៩៧៥ ដាក់ពន្ធនាគារកំណត់០៨(ប្រាំបី) ឆ្នាំ ពីបទៈជួញដូរគ្រឿងញៀន (ប្រព្រឹត្តច្រើនដង) ប្រព្រឹត្តនៅភូមិសាស្ត្រឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីដើមឆ្នាំ២០០៦ ដល់ថ្ងៃទី ១១-១០-២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៣ ថ្មី កថាខណ្ឌ២ ចំណុច"ក" នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០០៥។

៣-សម្រេចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សារ៉ាត់ ហៅ ហេង ភេទប្រុស កើតឆ្នាំ ១៩៥៣ និងឈ្មោះ [redacted] ចាន់ណា [redacted] ណាយ ភេទស្រី កើតឆ្នាំ ១៩៧៨ ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

៤-វត្ថុតាងៈ កុំព្យូទ័រយួរដៃ (Laptop) ម៉ាក Lenovo ពណ៌ទឹកប្រាក់លេខ S/N EB07093554 P/N R3 N037 B17437 Model Name 7757 ចំនួនមួយគ្រឿង ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

៥-សម្ភារៈផ្ទាល់ខ្លួនរួមមាន រូបថតទំហំ ១.៥០ម x ០,៩០ម មានរូបចំនួន ០៦នាក់ ចំនួនមួយសន្លឹក ,វិក័យប័ត្រធនាគារអេស៊ីលីដា ភីអិលស៊ី ចំនួនមួយសន្លឹក ,រូបថតទំហំ ០,៨ម x ០,៦ម ចំនួនបីសន្លឹក,-រូបថតតូចចំនួនដប់អាល់ប៊ុមតូច និងពីរអាល់ប៊ុមធំ ត្រូវប្រគល់ឱ្យម្ចាស់ដើមឈ្មោះ ជា ចាន់កេសរ វិញ។

៦-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៥-០៤-២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៧-០៥-២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ , ឈ្មោះ [redacted] ផាន ,ឈ្មោះ [redacted] អៀង , ឈ្មោះ [redacted] វណ្ណា កាំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ាត់ និងឈ្មោះ [redacted] ចាន់ជា។

ទុកសិទ្ធិប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**-បានឃើញ**ឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨-០៥-២០១២ របស់ឈ្មោះ [redacted] **ចាន់កេសរ** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩"ច" ចុះថ្ងៃទី ១៧-០៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ**ឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០-០៥-២០១២ របស់ឈ្មោះ [redacted] **វណ្ណា** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩"ច" ចុះថ្ងៃទី ១៧-០៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ**ឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៥-០៦-២០១២ របស់ឈ្មោះ [redacted] **ផាន** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩"ច" ចុះថ្ងៃទី ១៧-០៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ**របាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ១៧-១២-២០១២។



Scanned with CamScanner

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ២២-០១-២០១៣។

## **នាពេលសវនាការសាលាឧទ្ធរណ៍**

### ចៅក្រមអានរបាយការណ៍រឿង

-ឈ្មោះ [redacted]ផាន បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍ដោយមិនសុខចិត្តនឹងការផ្តន្ទាទោសខ្លួនច្រើនពេក ខ្លួនទិញគ្រឿងញៀនគ្រាន់តែយកមកប្រើប្រាស់ពីឈ្មោះ [redacted] អៀង ចំនួន ១ ឬ ២ថង់ យកមកប្រើប្រាស់ ដោយក្នុងមួយថង់មានខ្លះចំនួន ១០០ឬ ២០០គ្រាប់ និងប្រើប្រាស់ពីកន្លះខែទៅ ០១ខែ។ ក្នុងរឿងនេះខ្លួនមិនបានប្រព្រឹត្តទេ គ្រាន់តែបានទិញមកប្រើប្រាស់ដោយមានចំនួនច្រើន និងទិញជាច្រើនដង ខ្លួនសុំបដិសេធមិនបានយកទៅជួញដូរឱ្យអ្នកផ្សេងទេ ហើយទិញពីឈ្មោះ [redacted]វណ្ណា ក៏មានចំនួនដូចទិញពីឈ្មោះ [redacted] អៀង ដែរ។ ខ្លួនទិញថ្នាំនេះមកប្រើឆ្នាំ ២០០៦ និងត្រូវគេចាប់ខ្លួនឆ្នាំ២០១០ ចាប់តែខ្លួនម្នាក់ឯង ដោយឆែកឡានរបស់ខ្លួនចាប់តែម្តងមានរបស់ប្រើតែបន្តិចបន្តួចប៉ុណ្ណោះ។ ខ្លួនស្គាល់ឈ្មោះ [redacted] អៀង តាំងពីមុនមកពុំមានអ្នកណាណែនាំទេ និងទិញថ្នាំញៀននេះមកប្រើប្រាស់ជាមួយស្រីការ៉ាអូខេសប្បាយជាមួយគ្នា ដោយប្រើពីកន្លះខែទៅ ១ខែបានប្រើអស់ ហើយក្នុងការទិញដូចជាមិនលាក់លៀមអីទេ ជួនកាលទិញបណ្តាក់ក៏មានពីរជើងបីជើងគេយកលុយម្តង។ ខ្លួនសំណូមពរសុំឱ្យតុលាការលើកលែងចោទប្រកាន់។

-ឈ្មោះ [redacted] ចាន់កេសរ បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍ដោយមិនសុខចិត្តនឹងការផ្តន្ទាទោសចំពោះរូបខ្លួនអយុត្តិធម៌ ដោយខ្លួនមិនបានជួញដូរគ្រឿងញៀនដូចឈ្មោះ [redacted] អៀង ចោទខ្លួនទេ ខ្លួនអត់ទទួលស្គាល់ទេ ដោយមិនបានជួញដូរគ្រឿងដូចបទចោទទេ នេះជាចម្លើយដែលឈ្មោះ [redacted] អៀង ចោទមកលើខ្លួន។ នៅពេលចាប់ខ្លួនមកមិនបានដកហូតអ្វីទេ តែបញ្ជូនខ្លួនមកដល់ខេត្តបន្ទាយមានជ័យបានដកហូតយក Laptop របស់កូនប្រុសខ្លួនមួយគ្រឿង និងរូបថត នៅផ្ទះលេខ១៨ ខណ្ឌឫស្សីកែវ ពុំមានដកហូតបានគ្រឿងញៀនទេ ហើយការចាប់ខ្លួននៅថ្ងៃទី ១៩-០២-២០១១។ ខ្លួនស្គាល់ឈ្មោះ [redacted] អៀង ចុងឆ្នាំ២០០៨ ជាស្រីរបស់គាត់ដេករស់នៅជាមួយគ្នា មុនឆ្នាំ២០០៨ ពុំមានទំនាក់ទំនងជាមួយគាត់ទេ ដោយក្នុងឆ្នាំ ២០០៦-០៧ ខ្លួនរស់នៅស្ទឹងត្រែងជាអ្នករកស៊ីរាប់លុយ ខ្លួនស្គាល់ឈ្មោះ [redacted] អៀង តាមរយៈឈ្មោះ ប្រុស បើកហាងស្រីនៅខេត្តស្ទឹងត្រែងដែលបានចងការលុយខ្លួនចំនួន៥០០$ ហើយត្រូវបានគេចាប់ខ្លួនគាត់មកឃុំនៅ ប៉េស៊ី ខ្លួនមកសួរសុខទុក្ខគាត់ក៏បានជួបឈ្មោះ [redacted] អៀង ក្នុងឆ្នាំ២០០៧ ដែលពេលនោះខ្លួនកំពុងរស់នៅខេត្តស្ទឹងត្រែងនៅឡើយ គាត់ទូរស័ព្ទទំនាក់ទំនងខ្លួនរហូតដល់ចុងឆ្នាំ២០០៨ ដោយខ្លួនមិនដឹងថា គាត់មានទីលំនៅនៅឯណាផង គាត់បានមកលេងផ្ទះខ្លួនក៏មានទំនាក់ទំនងស្នេហាជាមួយគ្នា នៅផ្ទះម្តាយខ្លួននៅភ្នំពេញនៅពេលសមត្ថកិច្ចឃាត់ខ្លួនពុំបានរកឃើញវត្ថុតាងគ្រឿងញៀនអ្វីទេ ហើយបញ្ជីដែលឈ្មោះ [redacted] អៀង បានសរសេរដាក់មានឈ្មោះខ្លួនរកស៊ីគ្រឿងញៀនជាអក្សររបស់គេ ខ្លួនមិនបានដឹងឮ និងផ្តិតស្នាមមេដៃរបស់ខ្លួនផង ខ្លួនឈ្មោះ [redacted] ចាន់កេសរ មិនមែនឈ្មោះ [redacted]សរ ជាមនុស្សប្រុសនោះទេ។ ខ្លួននៅតែបដិសេធអ្វីដែលគាត់ទោសខ្លួនពីសាលាដំបូងមកពុំមានយុត្តិធម៌សំរាប់ខ្លួនទេ ហើយរាល់ទំនាក់ទំនងខ្លួនជាមួយឈ្មោះ [redacted] អៀង ជាស្នេហា



Scanned with CamScanner

ដេកនៅជាមួយគ្នា ដោយគាត់មិនឱ្យខ្លួនយកអ្នកណាទាំងអស់គឺរស់នៅកំដរគាត់រហូត ប៉ុន្តែខ្លួនចង់រស់នៅដោយមានសុភមង្គលមិនចង់មានការលាក់លៀមទេ រហូតដល់ខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ [redacted] រីឯប្ដីខ្លួនបានរៀបការត្រឹមត្រូវបានស្លាប់បាត់ហើយ។ រាល់ការទំនាក់ទំនងជាមួយឈ្មោះ [redacted] អៀង គឺជារឿងស្នេហាពុំមានគ្រឿងញៀនទេ ហើយអ្វីដែលគាត់ខឹងព្រោះចង់ដេករស់នៅជាមួយខ្លួនដោយបានទូរស័ព្ទមកខ្លួនរហូត ខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ ឈុន តាំងពីពាក់កណ្ដាលឆ្នាំ២០១០ ដោយឈ្មោះ [redacted] អៀង បានដឹងនៅចុងឆ្នាំ២០១០ ហើយនៅសាលាដំបូងឈ្មោះ [redacted] អៀង បានចូលក្នុងសវនាការក៏ខ្លួននៅតែរក្សាចម្លើយ ថាខ្លួនគ្រាន់តែជាស្រីរបស់គាត់ពុំមានពាក់ព័ន្ធគ្រឿងញៀនទេ។ ខ្លួនពុំដឹងថាឈ្មោះ [redacted] អៀង ជាប់ពន្ធនាគា និងទៅសួរសុខទុក្ខគាត់ទេ ហើយចំពោះឈ្មោះ [redacted] ផាន , [redacted] វណ្ណា មិនដែលស្គាល់និងទំនាក់ទំនងសោះតើរកស៊ីគ្រឿងញៀនម្ដេចទៅ ខ្លួនក៏មិនបានដឹងឈ្មោះ [redacted] អៀង នោះរកស៊ីអ្វីដែរដោយមិនដែលនិយាយប្រាប់ខ្លួន។ ខ្លួនសំណូមពរសុំតុលាការឱ្យខ្លួនរួចផុតពីការចោទប្រកាន់។

-ឈ្មោះ [redacted] វណ្ណា បានឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍មកដោយសារកាត់ទោសខ្លួនមិនប្រក្រតី ដែលខ្លួនគ្រាន់តែជាអ្នកប្រមូលលុយឱ្យគេជាប់ដល់០៨ឆ្នាំ ចំណែកម្ចាស់គ្រឿងញៀនជាប់តែពីរឆ្នាំ ដោយខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ មុនដំបូងឡើងគាត់ពឹងពាក់ឱ្យខ្លួនជួយដើរយកលុយឱ្យគាត់ តែពុំបានដឹងថាលុយនោះជាលុយអ្វីទេ ក្រោយមកខ្លួនបានដឹងថាជាលុយលក់គ្រឿងញៀន ខ្លួនក៏បានឈប់ទៅ។ ខ្លួនបានដើរប្រមូលលុយឱ្យឈ្មោះ [redacted] អៀង បានប្រហែលជា១០លើកជាង ប្រមូលពីឈ្មោះ [redacted], [redacted] ផាន , [redacted] ម៉ៃយើ, ដេវីត "ជនជាតិថៃ" យកទៅដាក់កន្លែងផ្ទះឈ្មោះ ធារ៉ា ដូរលុយនៅប៉ោយប៉ែត ដោយឈ្មោះ [redacted] អៀង ទូរស័ព្ទប្រាប់ខ្លួន និងនៅពេលខ្លួនទៅដល់គេណាត់យើងឱ្យទៅយកនៅកន្លែងណា១ មានចំនួន១០ម៉ឺន,២០ម៉ឺន បាត,៣០ម៉ឺនបាត ឬក៏៥០ម៉ឺនបាត មិនទៀង ខ្លួនមិនដឹងពីទំនាក់ទំនងឈ្មោះ ធារ៉ា និងឈ្មោះ [redacted] អៀង យ៉ាងម៉េចទេ ខ្លួនក៏ពុំមានការសង្ស័យដោយគាត់ពឹងពាក់ក្នុងមួយខែពីរឬ បីដង។ រហូតដល់ក្រោយមកគាត់ប្រាប់ខ្លួនថា ប្រាក់ប្រមូលនេះជាប្រាក់គ្រឿងញៀន ខ្លួនក៏ឈប់ទៅដោយការប្រមូលគ្មានប្រាក់ឈ្នួល ឬប្រាក់ខែទេ និងចុងក្រោយបានឱ្យប្រាក់ខ្លួនចំនួន២០០០$ ឱ្យខ្លួនធ្វើការគាត់បន្តទៀត ខ្លួនឈប់ធ្វើ។ សមត្ថកិច្ចចាប់ខ្លួននៅសៀមរាបកន្លែងលាងឡាន ហើយចម្លើយសារភាពនៅសមត្ថកិច្ចតាមហ្នឹងដែរ ខ្លួនមិនបានកាន់គ្រឿងញៀនចែកចាយនោះទេ និងក្រោយពីឈ្មោះ [redacted] អៀងជាប់ពន្ធនាគារខ្លួនមិនបានបន្តមុខរបរជួញដូរថ្នាំញៀនទេ នេះជាការចោទប្រកាន់ខ្លួនជាមួយឈ្មោះ [redacted] កេសរ ពីសំណាក់ឈ្មោះ [redacted] អៀង ប៉ុណ្ណោះ។ នៅពេលសមត្ថកិច្ចចាប់ខ្លួនហើយ ទើបធ្វើដីកាលើដំបូលឡានអានឱ្យខ្លួនស្ដាប់ ក្នុងការចាប់នេះមានតែកាតាបតូចមួយ និងឡានមួយ និងបានចុះទៅឆែកផ្ទះរបស់ខ្លួនទៀតក៏ពុំមានគ្រឿងញៀនដែរ ចំពោះរថយន្តគេបានដកហូតនៅសាលាដំបូងដែលអត់មានពាក់ព័ន្ធបទល្មើស និងចម្លើយទេ។ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] ចាន់កេសរ ទេ,ឈ្មោះ លឹម ផាន ខ្លួនស្គាល់។ ខ្លួនសំណូមពរសុំឱ្យតុលាការលើកលែងចោទប្រកាន់។

**<u>តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា</u>**

-ក្រោយពីបានស្ដាប់របាយការណ៍សង្ខេប ក៏ដូចការសួរដេញដោលជនជាប់ចោទទាំងបី



Scanned with CamScanner

នាក់ និងការសួរដេញដោលរបស់ក្រុមប្រឹក្សាជំនុំជម្រះ,មេធាវីការពារជនជាប់ចោទ ខ្លួនសុំកំណត់ និងមិនយល់ស្របទៅនឹងអង្គហេតុដែលមាននៅក្នុងរបាយការណ៍ទៅលើជនជាប់ចោទទាំងបីនាក់ហ្នឹងទេ។ តំណាងមហាអយ្យការសុំកំណត់នូវអង្គហេតុជាថ្មីវិញថា ពាក់ព័ន្ធនឹងជនជាប់ចោទដែលមានចំនួន០៥រូបនេះ តំណាងមហាអយ្យការកត់សំគាល់ឃើញថា មេក្លោងរកស៊ីជួញដូរគ្រឿងញៀនគឺឈ្មោះ [redacted] អៀង ទេ ហើយដែលត្រូវផ្តន្ទាទោសទាបជាងគេបំផុត។ ចំណែកឈ្មោះ [redacted] វណ្ណា គ្រាន់តែជាអ្នកដើរយកលុយឱ្យឈ្មោះ [redacted] អៀង ត្រូវផ្តន្ទាទោសចំនួន០៨ឆ្នាំ ,[redacted] ជាន ក៏ដូច្នោះដែរពាក់ព័ន្ធជួញដូរគ្រឿងញៀនត្រូវបានអយ្យការសាលាដំបូងដាក់ថា ប្រើប្រាស់គ្រឿងញៀនទៅវិញ ហើយក្នុងការឆ្លើយនៅតុលាការអំបាញ់មិញនេះបញ្ជាក់ថា ឈ្មោះ [redacted] ជាន កុហកតុលាការដោយគាត់ទិញគ្រឿងញៀនពី ១០០ទៅ២០០គ្រាប់ ទៅប្រើប្រាស់ជាមួយនារីកាវ៉ូខេពីរយៈពេលមួយខែទៅពីរខែ មិនមែនគាត់ប្រើគ្រឿងញៀនទេ គឺជួញដូរគ្រឿងញៀនទើបប្រើប្រាស់អស់។ ឈ្មោះ [redacted] អៀង ជាមេជួញដូរគ្រឿងញៀនដែលបានឆ្លើយដាក់ឈ្មោះ [redacted] កេសរ ជាស្រីស្នេហ៍របស់ខ្លួន តំណាងមហាអយ្យការអាចជឿថា ជាអ្នករងគ្រោះដែលឈ្មោះ [redacted] អៀង ចង់ឱ្យធ្វើស្រីស្នេហ៍ខ្លួនជារឿងហួតនោះ ហើយត្រូវបានផ្តន្ទាទោសធ្ងន់ជាងខ្លួនឯងមេជួញដូរគ្រឿងញៀន និងចោទប្រកាន់ស្រាលទៅទៀតជាប់ពីរឆ្នាំឥឡូវរួចបាត់ ទោះបីសមត្ថកិច្ចមិនបានដកហូតគ្រឿងញៀនពីជនជាប់ចោទទាំងបីមែនពិត យើងទទួលចម្លើយសារភាពរបស់ឈ្មោះ [redacted] ជាន និង ហាក់អៀង អាចយកជាការបានគាត់ធ្លាប់រកស៊ីគ្រឿងញៀន ប៉ុន្តែវត្ថុតាងដកហូតគ្រឿងញៀនដកហូតអត់បានទេ ហើយសមត្ថកិច្ចបែរជាសម្រេចដកហូតម៉ាស៊ីនកុំព្យូទ័រដែលមិនពាក់ព័ន្ធគ្រឿងញៀនសោះជាទ្រព្យសម្បត្តិរដ្ឋទៅវិញ ការដកហូតនេះជាការខុសច្បាប់សុំឱ្យលោកប្រធានក្រុមបរឹក្សាពិចារណាឡើងវិញដែរ និងសុំឱ្យពិចារណាការផ្តន្ទាទោសទៅលើឈ្មោះ [redacted] ចាន់កេសរ, [redacted] វណ្ណា ពីព្រោះមិនពាក់ព័ន្ធក្នុងការរកស៊ីជួញដូរគ្រឿងញៀនជាមួយឈ្មោះ [redacted] អៀងៗ ជាមេក្លោងក្នុងរឿងនេះ នេះជាការភ័ន្តច្រឡំមួយរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ។ តំណាងមហាអយ្យការសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើសេចក្តីសម្រេច និងអង្គហេតុនេះឡើងវិញ។

-មេធាវី [redacted] ចិន្តា ការពារសិទ្ធិឱ្យឈ្មោះ [redacted] ចាន់កេសរ បានធ្វើសេចក្តីសន្និដ្ឋានថា ក្នុងរឿងនេះកូនក្តីខ្លួនបានឆ្លើយបញ្ជាក់ច្បាស់ហើយថា គាត់មិនពាក់ព័ន្ធទៅនឹងការឆ្លើយដាក់របស់ឈ្មោះ [redacted] អៀង ទេ និងបានសំណូមពរនៅចំពោះមុខនេះជារឿងរបស់ឈ្មោះ អៀង និងអ្នកពាក់ព័ន្ធជាមួយឈ្មោះ អៀង ផ្សេងទៀត។ មូលហេតុនៃការឆ្លើយដាក់នេះកើតចេញពីរឿងស្នេហាសតិអារម្មណ៍ ការជិតជាមផ្លូវចិត្ត ការអន់ចិត្ត អញ្ចឹងហើយបានជាកូនក្តីរបស់ខ្លួនបញ្ជាក់ថា គាត់ស្គាល់ឈ្មោះ អៀង នៅចុងឆ្នាំ២០០៨ តែឈ្មោះ អៀង បានឆ្លើយថា ទិញគ្រឿងញៀនពីកូនក្តីខ្លួននៅឆ្នាំ២០០៦-០៧ នេះជាចំណុចទី១។ ចំណុចទី២ ដែលនាំឱ្យឆ្លើយដាក់គ្រង់ថា នៅពេលមានទំនាស់ស្នេហាជាមួយឈ្មោះ អៀង គាត់បានហាមកូនក្តីខ្លួនមិនឱ្យទាក់ទងជាមួយអ្នកណាផ្សេងទេ តែកូនក្តីខ្លួនមិនចង់លាក់លៀមតទៅទៀតក៏បានទំនាក់ទំនងស្នេហាជាមួយឈ្មោះ ឈុន ដូចគាត់បានលើកឡើង និងនៅពេលឈ្មោះ អៀង ចង់ជួបកូនក្តីខ្លួនៗ មិនបានទៅជួប ឬពន្យាពេលទៅជួប ព្រមទាំងតាមដានឃើញកូនក្តីខ្លួនស្រឡាញ់អ្នកផ្សេងក្នុងពាក់កណ្តាលឆ្នាំ២០១០ និងចំណុចមួយ

ទៀតនៅពេលកូនក្តីខ្លួនគេចវេសពីគាត់មាន«មុន ០៧ខែ» ដែលបញ្ជាក់ថាក្បត់ផ្លូវចិត្តគាត់ សុំឱ្យក្រុមប្រឹក្សាពិចារណាចំណុចនេះផងដែរ។ ចំណុចមួយទៀតពេលគេចាប់ខ្លួនឈ្មោះ អៀង ក្នុងឆ្នាំ ២០១១ កូនក្តីខ្លួនក៏មិនបានដឹងដែរ និងអត់មានរវីរវល់ទាក់ទងអីដែរ ដែលជាហេតុធ្វើឱ្យគាត់មានអារម្មណ៍ខឹងសម្បារខ្លាំងអាចជាត់នុំគុំគួន ពីព្រោះបើតាមស្មារតីរបស់លោក អៀង គាត់ឆ្លាតណាស់ ដែលឆ្លើយឱ្យស្រូបនឹងកាល ពេលវេលា ជាលក្ខណៈចាប់កំហុសមកលើកូនក្តីខ្លួន ហើយការចាប់ខ្លួនកូនក្តីខ្លួននៅផ្ទះម្តាយពុំមានឃើញភស្តុតាងទេ ទាក់ទងនឹងការឆ្លើយដាក់នេះ។ឈ្មោះ អៀង មានស្គាល់អ្នកទិញច្រើនដែលមិនទាក់ទងនឹងកូនក្តីខ្លួន ដែលមុនដំបូងគាត់ទិញពីឈ្មោះ ទូច ជាមេមួយ ហើយ បន្ទាប់មកទិញពីឈ្មោះ ហេង "[redacted] សារ៉ាត ឬ រ៉េត ចាន់ថា ហៅ ណយ" និងឈ្មោះ [redacted] សុខលាង និងប្រពន្ធមកលក់ឱ្យគាត់ និងឈ្មោះ ចៃគីម គឺមិនមែនកូនក្តីខ្លួនដែលគាត់ស្គាល់មួយទេ គឺស្គាល់មេដែលគាត់បានទិញច្រើន ហើយគាត់បានឆ្លើយទៀតថា ស្គាល់ឈ្មោះ ទ្រី "[redacted] សាច់ដុំ" ជាអ្នកផលិតខេទឹកកក ឬយ៉ាម៉ានៅកម្ពុជា និងឆ្លើយជំពាក់ជំពិនជាមួយអ្នកទិញពីគាត់អត់មានពាក់ព័ន្ធកូនក្តីខ្លួនដែរដូចជាឈ្មោះ ហើម, អ្នកផ្សេងៗ ទៀតដែលទិញបន្ត។ ចំណុចមួយទៀតឈ្មោះ អៀង មានអ្នកប្រមូលលុយគ្រឿងញៀនមានក្មួយគាត់ឈ្មោះ ហុង និងប្រពន្ធចុងគាត់ជាជនជាតិវៀតណាមក៏អត់មានពាក់ព័ន្ធកូនក្តីខ្លួនដែរ ហើយទាក់ទងនឹងវេរប្រាក់ពីប៉ោយប៉ែតមកភ្នំពេញ ដូចមានបញ្ជាក់នៅក្នុងកំណត់ហេតុស្រាប់ និងចំណុចសំខាន់មួយទៀតឈ្មោះ [redacted] ផាន [redacted] វណ្ណា មិនស្គាល់កូនក្តីខ្លួនទេពាក់ព័ន្ធតែឈ្មោះ អៀង ប៉ុណ្ណោះ ដែលស្របទៅនឹងតំណាងមហាអយ្យការបានលើកឡើង រីឯរឿងបញ្ជីកត់ឈ្មោះៗ អៀង បានបញ្ជាក់ច្បាស់គាត់កត់ឈ្មោះអ្នកទិញពីគាត់ និងអ្នកជំពាក់លុយគាត់ ដូច្នេះគាត់ជាមេទៅហើយទៅទិញអីពីកូនក្តីខ្លួន ហើយឈ្មោះ សរ ឬ ហ៊ាសរ ជាឈ្មោះអ្នកដទៃ។ ដូច្នេះនៅក្នុងគោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌក្តី រដ្ឋធម្មនុញ្ញក្តីដែលមានចែងអំពីវិមតិសង្ស័យត្រូវបានប្រយោជន៍ជនជាប់ចោទ ព្រោះក្នុងរឿងនេះពុំទាន់មានធាតុផ្សំ និងភស្តុតាងគ្រប់គ្រាន់ទេលើបទចោទប្រកាន់ គ្រាន់តែវិមតិសង្ស័យយកសំដីឈ្មោះ អៀង តែម្នាក់ឆ្លើយដាក់ អញ្ចឹងហើយការចោទប្រកាន់របស់សាលាដំបូងនៅមិនទាន់ត្រឹមត្រូវទេ សុំឱ្យក្រុមប្រឹក្សាសម្រេចបដិសេធសាលក្រមសាលាដំបូង និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទស្របតាមមាត្រា ៣៥១,៣៨ "រដ្ឋធម្មនុញ្ញ" បដិសេធបទចោទប្រកាន់លើកូនក្តីខ្លួនត្រង់មាត្រា ៤០៥ ក្រមនីតវិធីព្រហ្មទណ្ឌ និងសំណូមពរសុំឱ្យក្រុមប្រឹក្សានិងតំណាងមហាអយ្យការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបចោទប្រកាន់។

-មេធាវី [redacted] ម៉ាំង ការពារសិទ្ធិឱ្យឈ្មោះ [redacted] ផាន បានធ្វើសេចក្តីសន្និដ្ឋានថា តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអ្នកជាមេក្លោងធំជាងគេគឺឈ្មោះ [redacted] អៀង ទេ ហើយចម្លើយរបស់កូនក្តីខ្លួនតាំងពីសាលាដំបូងរហូតដល់សាលាឧទ្ធរណ៍នេះ គឺគាត់បានសារភាពហើយ ប៉ុន្តែសារភាពនេះទាក់ទងទឡ្ហីករគាត់បានប្រើថ្នាំនេះពី១០០-ទៅ២០០គ្រាប់ ដែលជាចម្លើយមួយពុំមានការប្រកែក ឬក៏តវ៉ាមិនសុខចិត្តដែរ គ្រាន់តែការប្តឹងឧទ្ធរណ៍របស់គាត់ត្រង់ការផ្តន្ទាទោសមានកំរិតខ្ពស់ដែគាត់មិនឯកភាព និងក៏មិនបានបដិសេធថា មិនបានទិញពីឈ្មោះ [redacted] អៀង ដែរ។នៅក្នុង



Scanned with CamScanner

ចំនួន១០០ទៅ ២០០គ្រាប់ ខ្លួនយល់ឃើញថា មានសារធាតុញៀនមានកំរិតទាប និងព្យសនកម្ម ទទួលបានក៏មានកំរិតទាប ហើយចម្លើយរបស់តាំងពីក្រោមមកពុំមានបង្ហាញថា គាត់ជាឈ្មួញកណ្ដាល ឬចែកចាយបន្តទៅឱ្យអ្នកទី៣ដែរ អ្វីដែលកូនក្ដីខ្លួនបានលើកឡើងនេះមិនមានឯកសារ ឬភស្តុតាងណាមួយ ឬសាក្សីពាក់ព័ន្ធថា កូនក្ដីខ្លួនយកចំនួន១០០ទៅ ២០០គ្រាប់ចែកចាយឱ្យជនទី៣បន្តទេ គឺរយៈពេលគាត់ប្រើកន្លះខែ ឬមួយខែ ដោយសារគាត់ឧស្សាហ៍ចូលការ៉ាអូខេមានស្រីស្នេហ៍ច្រើនប្រើប្រាស់រួមគ្នាដូចគាត់បានសារភាពក្នុងសវនាការនេះ។ ទាក់ទងចម្លើយរបស់ឈ្មោះ ហាក់អៀង ថាកូនក្ដីខ្លួនមានឈ្មោះក្នុងបញ្ជីជួញដូរគ្រឿងញៀនរបស់គេនោះ ខ្លួនសុំបដិសេធចោល ដោយសារពុំមានអ្វីសំគាល់កូនក្ដីខ្លួនផ្ដិតមេដៃទទួលរួមគំនិតរកស៊ីជួញដូរ ឬចែកចាយគ្រឿងញៀននោះទេ គ្រាន់តែជាសំដីរបស់គាត់ ហើយកូនក្ដីខ្លួនជាជនរងគ្រោះតែប៉ុណ្ណោះ។ ខ្លួនសំណូមពរសុំឱ្យពិចារណាអ្វីដែលកូនក្ដីខ្លួនបានសំដែងការស្មោះត្រង់តាំងពីសាលាដំបូងមក មេត្តាជួយបន្ធូបន្ថយទោសឱ្យកូនក្ដីខ្លួនមានកំរិតទាបបំផុត។

-មេធាវី [redacted] ចន្ថា ការពារសិទ្ធិឱ្យឈ្មោះ [redacted] វណ្ណា បានធ្វើសេចក្ដីសន្និដ្ឋានថា នៅក្នុងសវនាការថ្ងៃនេះកូនក្ដីខ្លួនបានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថា គាត់គ្រាន់តែបានដើរប្រមូលប្រាក់មិនមែនដើរប្រមូលប្រាក់ពីអំពើជួញដូរគ្រឿងញៀននោះទេ ព្រោះឈ្មោះ [redacted] អៀង ឱ្យកូនក្ដីខ្លួនប្រមូលប្រាក់ពីអ្នកដែលពាក់ព័ន្ធជាមួយ [redacted] អៀង តែប៉ុណ្ណោះ ដើម្បីយកប្រាក់ទៅវេរនៅផ្ទះឈ្មោះ ផាវ៉ា នៅប៉ោយប៉ែតមកផ្សារអូឡាំពិក ហើយបញ្ហានេះកូនក្ដីខ្លួនគ្រាន់តែអ្នកទទួលបញ្ជាពីឈ្មោះ [redacted] អៀង រីឯបញ្ហាពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀនកូនក្ដីខ្លួនមិនមានការពាក់ព័ន្ធដូចតំណាងអយ្យការចោទប្រកាន់នោះទេ ដូចតំណាងមហាអយ្យការបានបញ្ជាក់ច្បាស់លាស់រួចហើយ រាល់ទង្វើកូនក្ដីខ្លួនពុំមានភស្តុតាង ឬថ្នាំញៀនដែលនៅជាប់នឹងខ្លួននោះទេ ហើយពេលឃាត់ខ្លួនកូនក្ដីខ្លួនបើនិយាយពីនីតិវិធីផ្លូវច្បាប់ការចាប់ខ្លួនពុំមានដីកាចាប់ខ្លួនទេ គឺពេលចាប់គេធ្វើនៅដំបូលឡាន ហើយឆែកឆេរទាំងកន្លែងកើតហេតុ និងនៅផ្ទះ គឺពុំមានភស្តុតាងណាឬថ្នាំញៀនណាដាក់បន្ទុកទៅលើកូនក្ដីខ្លួនទេ ចំណុចដែលទាក់ទងជាមួយឈ្មោះ [redacted] កេសរ និង [redacted] ផាន កូនក្ដីខ្លួនបញ្ជាក់ថា មិនដែលស្គាល់ឈ្មោះ [redacted] កេសរ នោះទេ តែចំពោះឈ្មោះ [redacted] ផាន គាត់ស្គាល់តាមរយៈឈ្មោះ [redacted]-អៀង ឱ្យទៅទារលុយពីឈ្មោះនេះតែប៉ុណ្ណោះ និងទារលុយពីអ្នកផ្សេងទៀតដែលពាក់ព័ន្ធនឹងឈ្មោះ អៀង ដូចតំណាងមហាអយ្យការបានបញ្ជាក់ហើយឈ្មោះ [redacted] អៀង ជាមេក្លោងជួញដូរគ្រឿងញៀន រីឯការផ្ដន្ទាទោសមានរយៈពេល០២ឆ្នាំ ហើយអ្នកដែលប្រមូលលុយឱ្យក្រោយមកទើបដឹងថា លុយរបស់ឈ្មោះ [redacted] អៀង នេះសុទ្ធតែជាលុយអំពើពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀន ចំណុចនេះក្រោយកូនក្ដីខ្លួនបានដឹងក៏បានបញ្ឈប់រាល់សកម្មភាពមិនបានប្រព្រឹត្តបន្តទៅទៀតទេ រាល់ទង្វើដែលកូនក្ដីខ្លួនបានលើកឡើងគ្រប់ដំណាក់កាលនៃនីតិវិធីក៏ដូចជាចម្លើយតទល់ ថ្វីត្បិតតែឈ្មោះ [redacted] អៀង ដាក់បន្ទុកទៅលើកូនក្ដីខ្លួនៗ ក៏បានបញ្ជាក់ច្បាស់ថា ខ្លួនមិនបានពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀននេះទេ ម៉្យាងវិញទៀតកូនក្ដីខ្លួនជាមន្ត្រីនគរបាលទទួលបន្ទុកគ្រឿងញៀន រឿងអីដែលកូនក្ដីខ្លួនប្រព្រឹត្តអំពើជួញដូរគ្រឿងញៀននេះ។ ខ្លួនសំណូមពរយ៉ាងទទូចសុំឱ្យក្រុមប្រឹក្សាពិនិត្យពិចារណាទៅលើការកំណត់ទណ្ឌកម្មរបស់សាលាដំបូងដែលផ្ដន្ទាទោសកូនក្ដីខ្លួនធ្ងន់-

មហាធ្ងន់ និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យកូនក្តីខ្លួនទទួលបាននូវស្ថានសំរាលទោសមួយដ៍ទាបបំផុត។

-មេធាវី [redacted] អ៊ាវ ការពារសិទ្ធិឱ្យឈ្មោះ [redacted] វណ្ណា បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនសុំឯកភាពតាមការសន្និដ្ឋានរបស់សហភាគា [redacted] ចន្ថា ប៉ុន្តែសុំបន្ថែមថា ការចោទប្រកាន់កូនក្តីខ្លួនដោយផ្តន្ទាទោសដាក់គុក០៨ឆ្នាំ ក្នុងការប្រព្រឹត្តក្នុងចន្លោះឆ្នាំ២០០៦-២០១០ ហើយនៅក្នុងអង្គហេតុហ្នឹងក៏មានការច្របូកច្របល់ដែលក្នុងរឿងនេះកូនក្តីខ្លួនពាក់ព័ន្ធត្រឹមតែដើរប្រមូលលុយឱ្យឈ្មោះ [redacted] អៀង និងត្រូវតុលាការចោទប្រកាន់ដោយសំអាងលើចម្លើយរបស់ឈ្មោះ [redacted] អៀង មួយគត់ ឬក៏ថែមចម្លើយរបស់ឈ្មោះ [redacted] ផាន ប្រហាក់ប្រហែលគ្នាដែរ ប៉ុន្តែឈ្មោះ [redacted] អៀង ឆ្លើយដាក់កូនក្តីខ្លួនមានភស្តុតាងស៊ីសង្វាក់ឬអត់ គឺពិតជាអត់មានទេ ក្រៅពីចម្លើយរបស់គាត់ទទេរនោះឡើយ។ ចំណែកចម្លើយរបស់ឈ្មោះ [redacted] ផាន អត់មានពាក់ព័ន្ធជាមួយឈ្មោះ [redacted] វណ្ណា ទេ ដោយកន្លងមកឈ្មោះ [redacted] វណ្ណា ដើរប្រមូលលុយគាត់ស្មានតែជាអ្នកលក់ផ្ទាល់ ហើយក្នុងពេលសវនាការនេះឈ្មោះ [redacted] ផាន បានឆ្លើយច្បាស់ហើយអត់ពាក់ព័ន្ធឈ្មោះ [redacted] វណ្ណា ទេ គឺទិញពីឈ្មោះ [redacted] អៀង គឺវាស៊ីសង្វាក់នឹងចម្លើយឈ្មោះ [redacted] វណ្ណាៗ ជាអ្នកប្រមូលលុយឱ្យ។ ចម្លើយសាក្សីឈ្មោះ [redacted] ពូន ត្រូវបានតុលាការចោទប្រកាន់ដំបូង និងលើកលែងចោទវិញ គាត់បានឆ្លើយថាឈ្មោះ [redacted] វណ្ណា ជាអ្នកដើរប្រមូលលុយឱ្យឈ្មោះ [redacted] អៀង ជាចម្លើយដោះបន្ទុកយ៉ាងច្បាស់ ហើយនៅមានសាក្សីមួយទៀតឈ្មោះ [redacted] ស្រៀង បានឆ្លើយប្រហាក់ប្រហែលគ្នាថា ឈ្មោះ [redacted] វណ្ណា ជាអ្នកប្រមូលលុយវេរឱ្យឈ្មោះ [redacted] អៀង។ នេះជាសាក្សីដោះបន្ទុកដែលបញ្ជាក់ថាចម្លើយរបស់ឈ្មោះ [redacted] អៀង មិនអាចយកជាការបានទេ ដូច្នេះក្នុងរឿងនេះពុំមានភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] វណ្ណា ទេ តែបើសិនជាឈ្មោះ [redacted] វណ្ណា បានដឹងថា លុយនេះជាលុយបានពីលក់គ្រឿងញៀនហើយនៅតែប្រព្រឹត្តទៀត ក៏មិនត្រូវចោទគាត់ពីបទជួញដូរគ្រឿងញៀនដែរ គឺចោទពីបទ ទទួលផលចោរកម្ម ដែលមិនត្រូវដាក់ទោសដល់០៨ឆ្នាំដែរ។ បើសិនជាតុលាការយល់ឃើញថា ចម្លើយរបស់ឈ្មោះ [redacted] អៀង យកជាការបានហើយ រកស៊ីជួញដូរគ្រឿងញៀនមែន ក៏មិនត្រូវផ្តន្ទាទោសគាត់ចូលក្នុងចំណុចទី២ កន្លងមកតុលាការបានផ្តន្ទាទោសគាត់តាមមាត្រា ៣៣ កថាខណ្ឌទី៣ ចំណុច"ក" នៃច្បាប់ជួញដូរគ្រឿងញៀនឆ្នាំ២០០៥ ក៏គួរតែផ្តន្ទាទោសក្នុងចំណុច១ បានហើយ ។ ចោទឈ្មោះ [redacted] វណ្ណា រកស៊ីច្រើនដងអត់មានភស្តុតាងដាក់បន្ទុកផងហ្នឹង ម៉េចក៏យកទៅបញ្ចូលជាមួយគេរកស៊ីច្រើនដង បើចោទឈ្មោះ [redacted] អៀង ច្រើនដងវាសមព្រោះមានបទល្មើសផ្តន្ទាទោសច្រើននៅសាលាដំបូង។ ខ្លួនសំណូមពរទទូចថា យោងតាមអង្គហេតុហ្នឹងកូនក្តីខ្លួនមានទឹកចិត្តបើតុលាការមិនឱ្យរួចសោះ មិនលើកលែងសោះក៏គួរតែផ្តន្ទាទោសឱ្យបានសមរម្យចន្លោះពី០២ឆ្នាំ ទៅ០៥ឆ្នាំ។

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨-០៥-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ ,បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០-០៥-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៥-០៦-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ផាន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ

៣៩ច-ចុះថ្ងៃទី ១៧-០៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។ ធ្វើឡើងក្នុងកំណត់ច្បាប់តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។

២-កាលពីដើមឆ្នាំ២០០៦ ដល់ដើមឆ្នាំ ២០០៧ ឈ្មោះ [redacted] អៀង បានទិញថ្នាំញៀនពីឈ្មោះ [redacted] ចាន់កេសរ ដើម្បីយកទៅលក់ឱ្យឈ្មោះ [redacted] ផាន , ឈ្មោះ [redacted] និងឈ្មោះ ដេវីត ហើយឈ្មោះ [redacted] អៀង បានប្រើឈ្មោះ [redacted] វណ្ណា ឱ្យដើរប្រមូលប្រាក់ឱ្យដោយឱ្យកំរៃចំនួន ២០០០$។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ បានឆ្លើយបដិសេធថា ខ្លួនពុំមានការពាក់ព័ន្ធ និងការរកស៊ីជួញដូរគ្រឿងញៀនដូចការចោទប្រកាន់ទេ ខ្លួនគ្រាន់តែជាស្រីកំណាន់របស់ឈ្មោះ [redacted] អៀង តែប៉ុណ្ណោះ ក្រោយមកមានបញ្ហារឿងស្នេហាជាមួយឈ្មោះ [redacted] អៀង ទើបឈ្មោះនេះឆ្លើយថា ខ្លួនជាអ្នកលក់ថ្នាំញៀនឱ្យ សុំឱ្យតុលាការរកយុត្តិធម៌ដល់ខ្លួនផង។

៤-តាមចម្លើយរបស់ឈ្មោះ [redacted] ផាន បានឆ្លើយថា ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] អៀង ម្តង១០០គ្រាប់ ទៅ២០០គ្រាប់ ដើម្បីយកមកប្រើប្រាស់ ពុំដែលបានជួញដូរគ្រឿងញៀនឡើយ។

៥-តាមចម្លើយរបស់ឈ្មោះ [redacted] វណ្ណា បានឆ្លើយទទួលស្គាល់ថា ខ្លួនពិតជាធ្លាប់ដើរប្រមូលប្រាក់ឱ្យឈ្មោះ [redacted] អៀង ពិតប្រាកដមែន ប៉ុន្តែពុំដែលបានដឹងថា ប្រាក់ថ្លៃអ្វីទេ តែក្រោយពីបានដឹងថា ជាប្រាក់ថ្លៃលក់គ្រឿងញៀនខ្លួនក៏បញ្ឈប់សកម្មភាពតែម្តង។ ខ្លួនពុំដែលបានធ្វើការជួញដូរគ្រឿងញៀនដូចការចោទប្រកាន់ឡើយ។

៦-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ ,ឈ្មោះ [redacted] ផាន ,ឈ្មោះ [redacted] វណ្ណា បានឆ្លើយបដិសេធនូវអំពើប្រព្រឹត្តរបស់ខ្លួន។ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អៀង ជាមេក្លោងបានបញ្ជាក់ឱ្យឃើញថា ឈ្មោះ [redacted] ផាន ពិតជាបានទិញថ្នាំញៀនពីខ្លួនម្តងចំនួន ១០០ ទៅ២០០គ្រាប់ ប្រាកដមែន។ ហើយឈ្មោះ [redacted] វណ្ណា ជាអ្នកដើរប្រមូលប្រាក់ឱ្យខ្លួន។ ចំណែកឈ្មោះ [redacted] ចាន់កេសរ ធ្លាប់លក់គ្រឿងញៀនឱ្យខ្លួនមែន ចំណុចនេះគប្បីសភាព្រហ្មទណ្ឌពិចារណា។

៧-តាមអង្គហេតុ និងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អៀង ឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ ,ឈ្មោះ [redacted] ផាន , ឈ្មោះ [redacted] វណ្ណា ពិតជាមានធាតុផ្សំគ្រប់គ្រាន់ដើម្បីចោទប្រកាន់ពីបទៈ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅភូមិសាស្ត្រ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីដើមឆ្នាំ២០០៦ ដល់ដើមឆ្នាំ ២០០៧ ប្រាកដមែន។

៨-ផ្អែកតាមអង្គហេតុ ឃើញថាក្រោយពីមានការចាប់ខ្លួនឈ្មោះ [redacted] អៀង ដែលបានប្រព្រឹត្តកាលពីឆ្នាំ២០០៦ ដល់ដើមឆ្នាំ២០០៧ ហើយមានការឆ្លើយដាក់ពីជនជាប់ចោទរូបនេះទៅលើជនជាប់ចោទទាំងបីនាក់នេះ ក៏ឈានដល់ការចាប់ខ្លួនជនជាប់ចោទនៅឆ្នាំ ២០១០ និងឆ្នាំ ២០១១

ម៉្យាងទៀតតាមការបញ្ជាក់របស់ជនជាប់ចោទឈ្មោះ [redacted] ផាន ថាទិញម្តង១០០គ្រាប់ ទៅ២០០ គ្រាប់ តែប៉ុណ្ណោះ។ ម៉្យាងទៀតការចាប់ខ្លួនជនជាប់ចោទទាំងបីនេះ ពុំបានដកហូតវត្ថុតាងដើម្បីយកមកធ្វើកោសលវិច័យបញ្ជាក់អំពីបរិមាណនៃភាពសុទ្ធលើសារធាតុញៀននោះឡើយ។ ចំណុចនេះគប្បីសភាព្រហ្មទណ្ឌពិចារណាចំណុចនេះ ដើម្បីជាផលប្រយោជន៍ដល់ជនជាប់ចោទ ក៏ដូចជាផលប្រយោជន៍ច្បាប់ផងដែរ។

៩-ផ្អែកតាមអំណាចនៃសាលក្រមនេះ ឃើញថា ការសម្រេចផ្តន្ទាទោសឈ្មោះ [redacted] អៀង ដែលជាមេក្លោងក្នុងការជួញដូរគ្រឿងញៀននេះមានកំរិតទាប រីឯអ្នកទទួលទិញបន្តបែរជាផ្តន្ទាទោសមានកំរិតធ្ងន់ជាង ដូច្នេះគប្បីតុលាការពិចារណាចំណុចនេះផងដែរ ដើម្បីឱ្យមានកំរិតសមទណ្ឌរវាងជនជាប់ចោទដូចគ្នា។

១០-ជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ ,ឈ្មោះ [redacted] ផាន ,ឈ្មោះ [redacted] វណ្ណា មានធាតុផ្សំគ្រប់គ្រាន់ចោទប្រកាន់ពីបទៈ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅភូមិសាស្ត្រឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ តាមមាត្រា ៣៣ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មស្តីពីគ្រឿងញៀន។

១១-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់កេសរ និងឈ្មោះ [redacted] ផាន ពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តកាលពីដើមឆ្នាំ ២០០៦ និងដើមឆ្នាំ ២០០៧។ និងឈ្មោះ [redacted] វណ្ណា ប្រព្រឹត្តកាលពីដើមឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ នៅភូមិសាស្ត្រ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ តាមមាត្រា ៣៣ ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីគ្រឿងញៀន។

១២-សាលក្រមព្រហ្មទណ្ឌលេខ ៣៤"ច" ចុះថ្ងៃទី ១៧-៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ លើកលែងតែចំណុចទី១"ក"និង"ខ" និងចំណុចទី២ គប្បីកែប្រែជាថ្មីឡើងវិញ តាមការយល់ឃើញខាងលើ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងចុះថ្ងៃទី ២៨-៥-២០១២ របស់ជនជាប់ឈ្មោះ [redacted] ចាន់កេសរ ,បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០-៥-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៥-៦-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ផាន ទុកជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៤"ច" ចុះថ្ងៃទី ១៧-៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចទី១ "ក"និង"ខ" និងចំណុចទី២ ត្រូវកែប្រែប្រែជាថ្មីថាៈ





Scanned with CamScanner

ក/-កែប្រែទណ្ឌកម្មឈ្មោះ [redacted] ចាន់កេសរ មកត្រឹមចំនួន០៨ឆ្នាំ វិញ។

ខ/-កែប្រែទណ្ឌកម្មលើឈ្មោះ [redacted] ផាន មកត្រឹមចំនួន០៨ឆ្នាំ វិញ។

គ/-កែប្រែទណ្ឌកម្មលើឈ្មោះ [redacted] វណ្ណា មកត្រឹមចំនួន០៥ឆ្នាំ វិញ។

ឃ/-កែប្រែបញ្ញត្តិមាត្រា ៣៣ថ្មី កថាខណ្ឌទី២ ចំណុច"ក" មកមាត្រា ៣៣ថ្មី កថាខណ្ឌទី១ វិញ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់គ្រឿងញៀន។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤-ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល។

៥-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤-១២-២០១៣ ចំពោះមុខមេធាវី និងជនជាប់ចោទ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

| | |
|---|---|
| បានឃើញ | សាលាឧទ្ធរណ៍ថ្ងៃទី 06 ខែ 02 ឆ្នាំ ២០១៤ |
| ប្រធានសាលាឧទ្ធរណ៍ | ក្រឡាបញ្ជី |
| [redacted] | [redacted] |



Scanned with CamScanner